ទស្សនវិស័យៈការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable development for Cambodia

# កិច្ចប្រជុំសមាជិកភាព ប្រចាំឆ្នាំ លើកទី ២៩ របស់សមាជិក គ.ស.ក

## កាលបរិច្ឆេទ៖ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

## ទីកន្លែង៖ សណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ

## I. សេចក្តីផ្តើម

រយៈពេល ២៩ ឆ្នាំបន្ទាប់ពីបម្រើកិច្ចការដល់សមាជិក និងដៃគូដែលជាអង្គការសង្គមស៊ីវិលរបស់ខ្លួន គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) នឹងប្រារព្ធពិធីអបអរដល់សមិទ្ធិផល ស្មារតីសាគ្គីភាព និងផែនការសម្រាប់កិច្ចសហប្រតិបត្តិការអនាគតរបស់សមាជិកតាមរយៈកិច្ចប្រជុំប្រចាំឆ្នាំ។

កិច្ចប្រជុំប្រចាំឆ្នាំ ត្រូវបានទទួលស្គាល់ថាជាព្រឹត្តិការណ៍ធំបំផុតប្រចាំឆ្នាំសម្រាប់សមាជិក ដៃគូ និងមណ្ឌលអ្នកគាំទ្រនានា។ ស្របតាមបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន កិច្ចប្រជុំកំពូលប្រចាំឆ្នាំត្រូវបានរៀបចំធ្វើឡើងដើម្បីពិនិត្យមើលឡើងវិញនូវលទ្ធផលការងារចុងក្រោយ និងដើម្បីពិភាក្សាអំពីផែនការសម្រាប់ឆ្នាំនេះ និងឆ្នាំបន្ទាប់ ហើយនៅឆ្នាំនេះ កិច្ចប្រជុំប្រចាំឆ្នាំនឹងត្រូវការពេលកន្លះថ្ងៃ ពោលគឺរយៈពេលពេញមួយរសៀលនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩។

អ្នកចូលរួម/ភ្ញៀវកិត្តិយសប្រហែលពី ២០០ ទៅ ៣០០ នាក់ដែលជាសមាជិករបស់ គ.ស.ក ដៃគូ និងជាតួអង្គអភិវឌ្ឍ (មន្រ្តីរដ្ឋាភិបាល ដៃគូអភិវឌ្ឍអ្នកតំណាងរបស់អង្គការសង្គមស៊ីវិល និងវិស័យឯកជន) អ្នកតំណាងរបស់អង្គការសហគមន៍ និងយុវជន នឹងត្រូវបានអញ្ជើញឲ្យចូលរួម។

ចាប់តាំងពីការប្រែប្រួលរបត់នយោបាយ រហូតដល់របត់សង្គម និងសេដ្ឋកិច្ច កិច្ចប្រជុំសមាជិកភាពប្រចាំឆ្នាំនឹងនាំយកមកនូវការយល់ដឹង អំពីវិសាលភាពអភិវឌ្ឍរួម និងស្វែងរកដំណោះស្រាយកាន់តែប្រសើរ និងចាត់វិធានការនានា។ ជាមួយនឹងការចូលរួម និងកិច្ចសហប្រតិបត្តិការយ៉ាងសកម្មក្នុងចំណោមសមាជិក និងដៃគូ កិច្ចប្រជុំប្រចាំឆ្នាំគឺជាសួនច្បារនៃថ្នាលគំនិត សម្រាប់កំណើតនៃការលូតលាស់បន្ត។

## II. គោលបំណង

1. ដើម្បីឆ្លុះបញ្ចាំងលទ្ធផលការងារកន្លងមក និងដើម្បីអបអរសមិទ្ធិផលសំខាន់ៗ ដែលជាការចូលរួមចំណែកចំពោះការអភិវឌ្ឍប្រទេសកម្ពុជា។
2. ដើម្បីទទួលស្គាល់ការគាំទ្ររបស់សមាជិក និងភាពជាដៃគូ ក្នុងការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីលវិល។
3. ដើម្បីពង្រឹងកិច្ចសហការក្នុងចំណោមសមាជិករបស់អង្គការ គ.ស.ក និងដៃគូ សម្រាប់សកម្មភាពផ្សេងៗ ដូចជាផែនទីបង្ហាញផ្លូវអង្គការសង្គមស៊ីវិល ក្នុងការឆ្លើយតបកាន់តែប្រសើរចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍ។

## III. របៀបវារៈ

*ពេលរសៀល៖*

មតិស្វាគមន៍ & សុន្ទរកថាស្វាគមន៍

ការប្រកាសផ្លូវការអំពីគណៈកម្មាធិការប្រតិបត្តិឆ្នាំ២០១៨ និង២០១៩៖ សមិទ្ធិផលសំខាន់ៗ និងស្ថានភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ និងផែនការប្រតិបត្តិការ និងថវិកាប្រចាំឆ្នាំ២០១៩

ការថតរូបជាក្រុម & អាហារសម្រន់ & ការតាំងពិព័រណ៍របស់អង្គការជាសមាជិក

ការណែនាំទៅកាន់អង្គការសង្គមស៊ីវិលអំពីផែនទីបង្ហាញផ្លូវ

សរុបមតិ និងបិទកម្មវិធី

របៀបវារៈ

| ម៉ោង | ប្រធានបទ | អ្នកសម្របសម្រួល |
| --- | --- | --- |
| ១:៣០–២:០០ | ចុះឈ្មោះ | ក្រុមការងាររបស់ គ.ស.ក |
| ២:០០– ២:១៥ | ការណែនាំ និងគោរពភ្លេងជាតិ | អ្នកកាន់កម្មវិធី៖<br>▪ លោក ច័ន្ទ ភក្តី<br>▪ អ្នកស្រី ចាន់ សុម៉ាលី |
| ២:១៥–២:៣០ | របាំជូនពរ | អង្គការ Cambodian Living Arts |
| ២:៣០–២:៥០ | កិច្ចស្វាគមន៍ & សុន្ទរកថាបើក | **អ្នកស្រី Jenny Pearson**<br>សមាជិកគណៈកម្មាធិការប្រតិបត្តិឆ្នាំ ២០១៨ របស់អង្គការ គ.ស.ក |
| ២:៥០ –៣:១០ | **ការប្រកាសផ្លូវការអំពីគណៈកម្មាធិការប្រតិបត្តិឆ្នាំ២០១៨ និង ២០១៩៖**<br>កំណត់សម្គាល់សំខាន់ៗរបស់ប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិដែលនឹងចាកចេញ និងចូលកាន់តំណែងថ្មី | **អ្នកស្រី ស៊ិន ពុទ្ធារី**<br>ប្រធានផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍សមាជិកភាពរបស់ គ.ស.ក |

| ម៉ោង | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| ៣:១០–៣:៤០ | <u>សមិទ្ធិផលសំខាន់ៗ និងហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ និងផែនការប្រតិបត្តិការ និងថវិកាប្រចាំឆ្នាំ២០១៩៖</u><br>1. បទបង្ហាញអំពីសមិទ្ធិផលសំខាន់ៗប្រចាំឆ្នាំរបស់អង្គការ គ.ស.ក ក្នុងឆ្នាំ២០១៨ និងផែនការសម្រាប់ឆ្នាំ២០១៩<br>2. បទបង្ហាញអំពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ និងថវិកាសម្រាប់ឆ្នាំ២០១៩<br>**សំណួរ និងចម្លើយ** | ▪ **អ្នកស្រីបណ្ឌិត អែល សុធារី** ប្រធានកម្មវិធីនៃអង្គការ គ.ស.ក<br>▪ **លោក ឃន ប៊ុនថុង** ប្រធានផ្នែកប្រតិបត្តិការនៃអង្គការ គ.ស.ក |
| ៣:៤០–៤:០០ | **ថតរូបជាក្រុម សម្រាកអាហារសម្រន់ និងទស្សនាការតាំងពិព័រណ៍របស់អង្គការសមាជិក** | **ទាំងអស់គ្នា** |
| ៤:០០–៥:០០ | <u>**បទបង្ហាញ៖ លទ្ធផលរកឃើញអំពីការសិក្សាពីផែនទីបង្ហាញផ្លូវអង្គការសង្គមស៊ីវិល៖**</u><br>1. តើអ្វីគឺនិន្នាការរបស់អង្គការសង្គមស៊ីវិល?<br>2. តើអ្វីនឹងជាការវិវត្តរបស់អង្គការសង្គមស៊ីវិល?<br>3. តើអង្គការសង្គមស៊ីវិលនឹងរក្សានិរន្តរភាពបានយ៉ាងដូចម្តេចទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុ?<br>**សំណួរ និងចម្លើយ** | **អ្នកដឹកនាំការពិភាក្សា៖**<br>**លោក ម៉ម សម្បត្តិ**<br>នាយកប្រតិបត្តិអង្គការ DPA<br>**វាគ្មិន៖**<br>▪ **លោក លន់ បូរីទ្ធី** ទីប្រឹក្សាឯករាជ្យ<br>▪ **លោក ថេង សារឿន** នាយកប្រតិបត្តិអង្គការ CCFC<br>▪ **លោក ងិន សៅរ័ត្ន** នាយកប្រតិបត្តិអង្គការ CDPO |
| ៥:០០ – ៥:៣០ | **មតិសរុបកិច្ចប្រជុំ & បិទកម្មវិធី** | **លោក សៀង សារឿន**<br>នាយកប្រតិបត្តិអង្គការ គ.ស.ក |

***សម្គាល់៖*** *អ្នករៀបចំកម្មវិធីរក្សាសិទ្ធិក្នុងការផ្លាស់ប្តូររបៀបវារៈអាស្រ័យលើកត្តាពេលវេលា និងវាគ្មិនៗ។ រូបភាពមួយចំនួន និងគំនិតសំខាន់ៗ នឹងត្រូវបានដកស្រង់ និងចែករំលែកជាសាធារណៈតាមរយៈបណ្តាញសង្គមនិងគេហទំព័ររបស់អ្នករៀបចំកម្មវិធី។*

*http://www.ccc-cambodia.org/en/resources/event-archives*
*www.facebook.com/CCCsince1990*
*www.youtube.com/CCCambodia*